# សេចក្តីប្រកាសព័ត៌មាន
Press Release

## ស្តីពី
on

## សិក្ខាសាលាផ្សព្វផ្សាយ
Dissemination Workshop

## “ការវាយតម្លៃហានិភ័យថ្នាក់ជាតិពាក់ព័ន្ធនឹងការសម្អាតប្រាក់ក្នុងវិស័យបរធនបាលកិច្ច”
“National Risk Assessment Related to Money Laundering in Trust Sector”

ថ្ងៃព្រហស្បតិ៍ ១រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣
Phnom Penh, April 6, 2023

នាព្រឹកថ្ងៃព្រហស្បតិ៍ ១រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣, នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍន៍ធុរៈកិច្ច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.)** អមដោយ ឯកឧត្តមអគ្គនាយករង ប្រធាននាយដ្ឋាន និងសហការី បានអញ្ជើញដឹកនាំ និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី “ការវាយតម្លៃហានិភ័យថ្នាក់ជាតិពាក់ព័ន្ធនឹងការសម្អាតប្រាក់ក្នុងវិស័យបរធនបាលកិច្ច” ដើម្បីផ្សព្វផ្សាយ និងពិភាក្សាអំពីវិធីសាស្រ្តវាយតម្លៃខ្លួនឯងរបស់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ក្នុងគោលបំណងធានាបាននូវប្រសិទ្ធភាព និងអនុលោមភាព តាមអនុសាសន៍ស្នូលរបស់ FAFT លើការវាយតម្លៃហានិភ័យពាក់ព័ន្ធនឹងការសម្អាតប្រាក់ក្នុងវិស័យបរធនបាលកិច្ច។ សិក្ខាសាលាផ្សព្វផ្សាយនេះ មានការចូលរួមពីតំណាងបុគ្គលរាយការណ៍ ដែលជាបរធនបាល, ប្រតិបត្តិករបរធនបាល និងក្រុមហ៊ុនវាយតម្លៃ និងតំណាងបុគ្គលពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច សរុបចំនួន ៧៩ រូប។

In the morning of Thursday, April 6, 2023, the Trust Regulator (TR) at Business Development Center, H.E. SOK Dara, Director General of The Trust Regulator (TR), Accompanied by H.E. Deputy Director Generals of the TR, Directors of Department and his colleagues, chaired and conducted the dissemination workshop on “National Risk Assessment Related to Money Laundering in Trust Sector” to disseminate and discuss about methodology of self-assessment for reporting entities in trust sector in order to ensure the effectiveness and compliance with FAFT’s recommendations on the risk assessments related to money laundering in trust sector. This dissemination workshop was attended by the Trustees, Trust operators, Appraisal Companies, and relevant stakeholders total of 79 participants.